# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០៣-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០០១ ស្តីពី ការតែងតាំងឯកឧត្តមចំនួន ០៤ រូបជាឧបការី សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៣៧

០៨-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០០៤ ស្តីពី ការតែងតាំងឯកឧត្តម **ម៉ុន ឋារិទ្ធ** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ១៣៨

១៤-០១-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០១០៥/០១១ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ុង អឿន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ និងទេសចរណ៍ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ១៣៩

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

១២-០១-២០០៥ -អនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពី ការបង្កើតទូរគមនាគមន៍កម្ពុជាជាសហគ្រាសសាធារណៈ ១៤០

១៤-០១-២០០៥ -អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពី ការកែតម្រូវឡើងវិញមាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ ១៥០

១៤-០១-២០០៥ -អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពី ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ១៥៦

១១-០១-២០០៥ -អនុក្រឹត្យលេខ ១៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៥៨

១១-០១-២០០៥ -អនុក្រឹត្យលេខ ១៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៦០

១២-០១-២០០៥ -អនុក្រឹត្យលេខ ២០ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៦១

១២-០១-២០០៥ -អនុក្រឹត្យលេខ ២១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១៦២

១២-០១-២០០៥ -អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃ
ធនាគារអភិវឌ្ឍន៍ជនបទ ១៦៣
១២-០១-២០០៥ -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៦៥
១២-០១-២០០៥ -អនុក្រឹត្យលេខ ២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦៧
១៣-០១-២០០៥ -អនុក្រឹត្យលេខ ២៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៨
១៣-០១-២០០៥ -អនុក្រឹត្យលេខ ២៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៦៩
១៣-០១-២០០៥ -អនុក្រឹត្យលេខ ២៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧០
១៣-០១-២០០៥ -អនុក្រឹត្យលេខ ២៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧១
១៣-០១-២០០៥ -អនុក្រឹត្យលេខ ២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧២
១៣-០១-២០០៥ -អនុក្រឹត្យលេខ ៣០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៣
១៤-០១-២០០៥ -អនុក្រឹត្យលេខ ៣១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៧៤

## ២. សេចក្តីសំរេច

១០-០១-២០០៥ -សេចក្តីសំរេចលេខ ០២ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីកំណត់អត្តសញ្ញាណពលករកម្ពុជាដែលកំពុងធ្វើការខុសច្បាប់នៅព្រះរាជាណាចក្រថៃ ១៧៦
១១-០១-២០០៥ -សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំសន្និសីទការឆក់ឱកាសនៃសកលភាវូបនីយកម្ម-យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងយុគសម័យនៃពាណិជ្ជកម្មសេរី នៅរាជធានីភ្នំពេញ ពីថ្ងៃទី ១០ ដល់ ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥ ១៧៩

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង :

១- លោក គួប សារឿន ជាឧបការី សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

២- លោកជំទាវ ហួង សាងលៀង ជាឧបការី សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

៣- លោកស្រី អឿន ស្រីមុំ ជាឧបការី សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៤- កញ្ញា ឡូច សុភា ជាឧបការី សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥០១.០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០០៥

លេខ ០៤ ស.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០១ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាវ ឌី តាន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ម៉ិន ថាវឫទ្ធិ** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ.ល. ០៥០១.០០៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៥

លេខ ០៥ . ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សៅ ឌី ស៊ុន**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០១១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យង់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **អ៊ុង អឿន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទ និងទេសចរណ៍ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៣៧ . ០៥០១ - ០១១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៥*

លេខ : ០៣ . ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សោ ខុន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ.....០.១..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

ត្រូវបានបង្កើត **ទូរគមនាគមន៍កម្ពុជា** អក្សរកាត់ថា **ទ.ក.** ជាភាសាអង់គ្លេស **TELECOM CAMBODIA** អក្សរកាត់ថា **T.C.** ។

**ទ.ក.** ជាសហគ្រាសសាធារណៈ មានលក្ខណៈជាក្រុមហ៊ុនរដ្ឋ ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រោមអាណាព្យាបាល ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ទ.ក.** មានទីស្នាក់ការនៅរាជធានីភ្នំពេញ អាស័យដ្ឋានលេខ ៩៥-៩៧ វិថីព្រះសីហនុ កែងផ្លូវលេខ ១០៥ សង្កាត់បឹងព្រលឹត ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ និងអាចផ្លាស់ប្តូរទីកន្លែងបានតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**ទ.ក.** ជានីតិបុគ្គលមានស្វ័យភាពបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។

**មាត្រា២._**

**ទ.ក.** ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្ម ស្របតាមកម្មវត្ថុរបស់ខ្លួន ។

**ទ.ក.** មានទិសដៅ និងភារកិច្ច ដូចខាងក្រោម ៖

១ - ធ្វើប្រតិបត្តិការបណ្តាញ និងផ្តល់សេវាទូរគមនាគមន៍ក្នុងប្រទេស និងក្រៅប្រទេស (Domestic and International Telecommunications Network Operator and Services Provider) តាមប្រព័ន្ធវិទ្យុគមនាគមន៍ (Radio Communications) តាមផ្កាយរណប (Satellite) ខ្សែកាបអុបទិក (Optical Fiber Cable) តាមខ្សែកាបក្រោមបាតសមុទ្រ (Sub-Marine Cable) ក្នុងនោះរួមមាន ៖

១.១- ត្រាផិកទូរស័ព្ទ និង ទូរសារ ( Telephone & Fax Traffic ) ។

១.២- គមនាគមន៍ទិន្នន័យ ( Data Communication ) ។

១.៣- អ៊ិនធឺណែត និង សារអេឡិចត្រូនិក ( Internet and E-mail ) ។

១.៤- បរិបថជួលជាវ ( Private Leased Circuit ) (PLC) ។

២- ផ្តល់សេវាលើការបញ្ជូនរូបភាពដោយផ្ទាល់ (TV Transmission point to point ) ។

៣- ផ្តល់សេវាលើការប្រើប្រាស់ប្រព័ន្ធផ្កាយរណបតូចៗ (VSAT System) ។

៤- ធ្វើសេវាកម្មវិស័យទូរគមនាគមន៍ ព្រមទាំងព័ត៌មានវិទ្យានៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលស្របតាមអាជ្ញាប័ណ្ណចេញដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

៥- ធ្វើឱ្យវិស័យទូរគមនាគមន៍ និង ព័ត៌មានវិទ្យានៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានការរីកចំរើន និងទំនើបទៅតាមបច្ចេកវិជ្ជា ។

៦- ផ្តល់សេវាវិស័យទូរគមនាគមន៍ផ្សេងៗទៀត ។

៧- សហការជាមួយក្រុមហ៊ុនក្នុងប្រទេស ឬ ក្រៅប្រទេស ក្នុងការធ្វើសេវាកម្ម អាជីវកម្ម ។

៨- ចុះកិច្ចសន្យាជួលជំនាញការតាមសេចក្តីត្រូវការ ។

៩- ចុះកិច្ចសន្យាជួលជាវប្រព័ន្ធទូរគមនាគមន៍នានា ជាមួយក្រុមហ៊ុនក្នុងប្រទេស ឬ ក្រៅប្រទេស ។

១០- កំណត់ថ្លៃសេវាទូរស័ព្ទក្នុងប្រទេសដោយខ្លួនឯង ឯថ្លៃសេវាទូរស័ព្ទអន្តរជាតិអនុវត្តតាម ចន្លោះថ្លៃមួយ ដែលត្រូវបានកំណត់ដោយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

១១- បង្កើតសាខានានាក្នុងព្រះរាជាណាចក្រកម្ពុជា ។

១២- ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនក្នុងប្រទេស ឬក្រៅប្រទេសក្នុងការផលិត ឬតម្លើងឧបករណ៍ បរិក្ខារខាងវិស័យទូរគមនាគមន៍ និងព័ត៌មានវិទ្យា ។

១៣- មានសិទ្ធិក្នុងការសុំចូលដល់ទីកន្លែងសាធារណៈ ឬលំនៅដ្ឋានឯកជន ដើម្បីតម្លើង ឬជួសជុលបណ្តាញ ទូរគមនាគមន៍ ស្របតាមសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា៣.-**

**ឧ.ក.** ត្រូវគោរពរបបពន្ធ និង អាករស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា៤.-**

ដើមទុនដំបូងរបស់ **ឧ.ក.** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលទទួលការឯកភាពពី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ពេលអនុក្រឹត្យនេះចូលជាធរមាន **ឧ.ក.** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលរដ្ឋបានប្រគល់អោយហើយដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា៥.–**

បុគ្គលិករបស់ **ឧ.ក.** ត្រូវជ្រើសរើសពីចំណោមមន្ត្រីនៃមុខងារសាធារណៈ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអាចជ្រើសរើសតាមកិច្ចសន្យាក្នុងករណីចាំបាច់ ។ បុគ្គលិករបស់ **ឧ.ក.** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈ ដោយឡែក ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ២
## ការដឹកនាំ និង ការគ្រប់គ្រង

**មាត្រា៦.–**

**ឧ.ក.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងពេញលេញ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និង លក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប | ជាប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | ជាសមាជិក |
| - តំណាងក្រសួង មហាផ្ទៃ | ១រូប | ជាសមាជិក |
| - អគ្គនាយក **ឧ.ក** . | ១រូប | ជាសមាជិក |
| - តំណាងនិយោជិតរបស់ **ឧ.ក.** | ១រូប | ជាសមាជិក |
| - តំណាងសភាពាណិជ្ជកម្ម | ១រូប | ជាសមាជិក |

**មាត្រា៧.–**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរៈជនដែលមានអាយុមិនលើសពី៦៥ (ហុកសិបប្រាំ) ឆ្នាំ និងមានបទពិសោធការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និង មិនដែលត្រូវផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ (បី) ឆ្នាំ ។ អាណត្តិនេះអាច

បញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬ អង្គភាពដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **ឧ.ក.** ។

**មាត្រា៨.–**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសម្រេចក្នុងនាម **ឧ.ក.** ក្នុងការរៀបចំលិខិតស្នាម ឯកសារផ្សេងៗ ទាក់ទងទៅនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ ៖**

១- សម្រេចលើគំរោងផែនការរបស់សហគ្រាស ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ

២- វាយតម្លៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសម្រួលឱ្យបានសមស្របតាមសភាពការណ៍

៣- លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ឧ.ក.**

៤- លើសំណើសមស្របរបស់អគ្គនាយក នូវរចនាសម្ព័ន្ធនិងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិកដោយអនុលោមតាម ច្បាប់ និង បទប្បញ្ញត្តិទាំងឡាយជាធរមាន

៥- សម្រេចលើកិច្ចសន្យា និងអនុសញ្ញាដែល **ឧ.ក.** ជាភាគីហត្ថលេខី ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន

៦- បង្កើត បើក ឬបិទការិយាល័យ និងទីស្នាក់ការគ្រប់កន្លែងរបស់ **ឧ.ក.** តាមការវិនិច្ឆ័យរបស់ខ្លួន។

៧- លើការប្រើប្រាស់ប្រាក់ចំណេញរបស់ **ឧ.ក.** ស្របតាមលក្ខន្តិកៈរបស់ **ឧ.ក.**

៨- លើការជួលជំនាញការ ឬ ការជួលបណ្តាញទូរគមនាគមនី

៩- លើកិច្ចសន្យាស្របតាមប្រកាសលេខ ៩៩៧ សហវ.ទរ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

**មាត្រា៩.–**

ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំនៅពេលណាក៏បាន អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានចំនួន ៤ (បួន) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច មួយដងក្នុងរយៈពេល ៣(បី)ខែ។

ករហើយប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ដែលមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដែលមានវត្តមានដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និង មន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច១០( ដប់)ថ្ងៃ មុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបាន លុះហោតែមានវត្តមានសមាជិកយ៉ាងតិច ៤( បួន) នាក់ ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥( ដប់ប្រាំ) ថ្ងៃ ក្រោយទៀត ដើម្បីពិភាក្សាលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា១០.–**

សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥( ដប់ប្រាំ) ថ្ងៃយ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយហើយត្រូវចម្លង ចូលបញ្ជីដែលមានលេខរៀងទំព័រជាហូរហែរ និងមានអត្តលេខចំណាំត្រឹមត្រូវ ។

កំណត់ហេតុដើមត្រូវមានចុះហត្ថលេខា ដោយប្រធានអង្គប្រជុំ សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលវត្តមាន និង លេខាធិការជ្រើសរើសដោយអគ្គនាយក ។

**មាត្រា១១.–**

អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងការងារ ជាប្រក្រតីនៃ **ឱ.ក.** នឹងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ (បី) ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ តំណែងនេះអាចបន្តទៅទៀតបាន តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**មាត្រា១២.–**

ក្រុមប្រឹក្សាភិបាលណែនាំ និង ប្រគល់ឱ្យអគ្គនាយកនូវអំណាចចាំបាច់ទាំងឡាយ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ ។

ក្នុងមុខងារនេះ អគ្គនាយកមានភារកិច្ច ៖

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច និង ចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនិមួយៗ និងត្រូវរាយការណ៍ជូន ក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ឧ.ក.**

២- ដឹកនាំ **ឧ.ក.** លើផ្នែករដ្ឋបាល បច្ចេកទេសអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ

៣- ជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងគ្រប់គ្រងបណ្តោភ្នាក់ងារ ឬមន្ត្រីគ្រប់រូប ដែលជានិយោជិតរបស់ **ឧ.ក.** ដោយគោរពតាមលក្ខន្តិកៈក្រុមហ៊ុន លក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាន និងតាមការសសម្រេចរបស់ក្រុមប្រឹក្សាភិបាល

៤- ផ្ទេរអំណាចមួយភាគឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រី ដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល

៥- ធ្វើជាតំណាងឱ្យ **ឧ.ក.** និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់តវ៉ាការពារក្តីឱ្យ **ឧ.ក.** និងប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា១៣._**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១៤._**

ការចុះនិងអនុវត្តន៍កិច្ចសន្យាដោយ**ឧ.ក.** ត្រូវគោរពតាមបែបបទនិងនីតិវិធី ដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន ។

## ជំពូកទី ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១៥._**

**ឧ.ក.** កាន់កាប់គណនេយ្យរបស់ខ្លួន ឱ្យបានស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖

- ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំ ដដែល
- របាយការណ៍ហិរញ្ញវត្ថុត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី ៣១ ខែមិនា នៃការិយបរិច្ឆេទបន្ទាប់
- របាយការណ៍ហិរញ្ញវត្ថុ ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងមិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនោះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទបញ្ញត្តិ នៃមាត្រា ២០ ២១ ២២ ២៣ ២៤ និងមាត្រា២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ។

**មាត្រា១៦._**

រៀងរាល់ឆ្នាំ មុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការប្រចាំឆ្នាំរបស់**ឧ.ភ.**តាមសំណើរបស់អគ្គនាយកហើយបញ្ជូន ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា១៧._**

**ធនធាន** នៃ **ឧ.ភ.** ជាអាទិ៍មាន ៖

- ដើមទុនដែលរដ្ឋផ្តល់ឱ្យ (តុល្យការដំបូងនៅពេលបង្កើត)
- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យបន្ថែម
- ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពសេវាកម្មរបស់ **ឧ.ភ.**
- ប្រាក់បានមកពីការលក់ ឬជួលចលនវត្ថុ និងអចលនវត្ថុ របស់ **ឧ.ភ.**
- ប្រាក់បានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា១៨._**

**ចំណាយ** នៃ **ឧ.ភ.** រួមមាន ៖

- ចំណាយប្រក្រតីសម្រាប់ដំណើរការ
- ចំណាយវិនិយោគ
- ចំណាយសងបំណុល
- ចំណាយផ្សេងៗ ។

**មាត្រា១៩.–**

**ឆ.ក.** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សម្រាប់តម្រូវការរបស់ខ្លួន ។

**មាត្រា២០.–**

**ឆ.ក.** ត្រូវបង់ប្រាក់ចំណូលដុលចូលថវិការដ្ឋ ៥១% ( ហាសិបមួយភាគរយ ) ពីសេវាទូរគមនាគមន៍អន្តរជាតិ ដូចប្រកចេញអន្តរជាតិទី២ និង ចំនួន៥% ( ប្រាំភាគរយ ) លើចំណូលទូរគមនាគមន៍ក្នុងប្រទេស និងសេវាតម្លៃបន្ថែម ។ ចំណែកឯប្រាក់ចំណេញ ត្រូវបង់ចូលថវិកាជាតិទាំងអស់ ឬមួយផ្នែក ឬរដ្ឋអាចរក្សាទុកទាំងអស់ឱ្យសហគ្រាសក្នុងករណីដែលរដ្ឋពិនិត្យឃើញថា ធ្វើការអភិវឌ្ឍជាចាំបាច់ ។

**មាត្រា២១.–**

រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២២.–**

រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ យ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ឆ.ក.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- គម្រោងផែនការរបស់ **ឆ.ក.**
- របាយការណ៍សកម្មភាព-របាយការណ៍ហិរញ្ញវត្ថុទាំងឡាយរបស់ **ឆ.ក.** ។

**មាត្រា២៣.–**

ត្រូវបានដាក់ឱ្យនៅអម **ឆ.ក.** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសម្លេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០ ២១ ២២ ២៣ ២៤ និងមាត្រា២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា២៤.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២៥.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..០២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែតម្រូវឡើងវិញមាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃ អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកងយោធពល-ខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និង ពិការ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** មាត្រា ៣ មាត្រា ៦ និង មាត្រា ៧ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និង ពិការ ត្រូវបានកែតម្រូវឡើងវិញដូចតទៅ :

មាត្រា៣ថ្មី : ការវាយតម្លៃប្រភេទថ្នាក់ពិការ គឺត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយ របស់ក្រសួងការពារជាតិ ដោយផ្អែកតាមប្រកាសអន្តរក្រសួង ដែលមានសមាសភាព :

- ក្រសួងការពារជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

មាត្រា៦ថ្មី : យោធិនទាំងពីរភេទ ដូចមានចែងក្នុងមាត្រា ២ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ :

ក- ចំពោះយោធិនពិការប្រភេទ "ក" គ្រប់កំរិតថ្នាក់ :

១- ក្រោយពេលព្យាបាលជម្ងឺរបួស ជាសះស្បើយ និងមានលំនឹង ត្រូវបានទទួលរបបឧបត្ថម្ភបំប៉នសុខភាពនៅមជ្ឈមណ្ឌលបំប៉នសុខភាព តាមរយៈពេលកំណត់ និងតាមកំរិតថ្នាក់ពិការ គឺ :

- កំរិតថ្នាក់ ១ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនកៅសិប (៩០) ថ្ងៃ
- កំរិតថ្នាក់ ២ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនហុកសិប (៦០) ថ្ងៃ
- កំរិតថ្នាក់ ៣ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនសែសិបប្រាំ (៤៥) ថ្ងៃ
- កំរិតថ្នាក់ ៤ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួនសាមសិប (៣០) ថ្ងៃ

២- យោធិនពិការ ប្រសិនបើនៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ បានទទួលរបបឧបត្ថម្ភជំនួយមុខរបួសបន្ថែមជាប្រចាំខែ ដោយគិតជាសមាមាត្រភាគរយនៃបៀវត្ស សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមកំរិតថ្នាក់ពិការ គឺបន្ថែមលើប្រាក់បៀវត្សប្រចាំខែផ្ទាល់ខ្លួន ។

- កំរិតថ្នាក់ ១ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសែសិបប្រាំ (៤៥) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ២ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសែសិប (៤០) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៣ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសាមសិបប្រាំ (៣៥) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៤ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹងសាមសិប (៣០) ភាគរយនៃប្រាក់បៀវត្ស ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ ។

៣- យោធិនពិការ ដែលក្រសួងការពារជាតិសម្រេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលរបបឧបត្ថម្ភប្រាក់អតីតភាពបំរើការងារមិនលើសពីម្ភៃបួន (២៤) ខែ ដោយគិតរយៈពេលបំរើកងយោធពលខេមរភូមិន្ទ ក្នុងមួយ (១) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួនពីរ (២) ខែ ។ ចំពោះយោធិនពិការដែលបំរើកងទ័ពមិនទាន់គ្រប់រយៈពេលមួយ (១) ឆ្នាំ ហើយត្រូវពិការក៏ត្រូវបានទទួលប្រាក់អតីតភាពចំនួនពីរ (២) ខែដែរ ។

៤- យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភមួយលើកដំបូង ស្មើនឹងទឹកប្រាក់ចំនួន :

- កំរិតថ្នាក់ ១ ទទួលទឹកប្រាក់សរុបចំនួនដប់ពីរ (១២) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ២ ទទួលទឹកប្រាក់សរុបចំនួនដប់ (១០) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៣ ទទួលទឹកប្រាក់សរុបចំនួនប្រាំបី (០៨) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

- កំរិតថ្នាក់ ៤ ទទួលទឹកប្រាក់សរុបចំនួនប្រាំមួយ (០៦) ខែ នៃប្រាក់បៀវត្សសរុបចុងក្រោយរបស់យោធិនពិការនោះ ។

៥- បានបន្តទទួលបើកប្រាក់បៀវត្សសរុបប្រចាំខែ ហើយបៀវត្សសរុបនោះត្រូវគិតតាមឋានន្តរសក្តិចុងក្រោយ មុនពេលសម្រេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ និងចំនួនកូននៅក្នុងបន្ទុកជាក់ស្តែងរបស់យោធិនពិការ ។

៦- យោធិនពិការដែលរស់នៅក្នុងមណ្ឌល យោធិនដែលចេញពីជួរកងយោធពលខេមរ-ភូមិន្ទ ត្រូវបានទទួលបន្ថែមនូវប្រាក់ឧបត្ថម្ភជំនួយមុខរបួសជារៀងរាល់ខែ ដោយគិតជាសមាមាត្រលើប្រាក់បៀវត្សសរុបប្រចាំខែ ដូចខាងក្រោម :

- កំរិតថ្នាក់ ១ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងមួយរយ ( ១០០ ) ភាគរយ

- កំរិតថ្នាក់ ២ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងប៉ែតសិប ( ៨០ ) ភាគរយ

- កំរិតថ្នាក់ ៣ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងហុកសិប ( ៦០ ) ភាគរយ

- កំរិតថ្នាក់ ៤ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹងសែសិប ( ៤០ ) ភាគរយ

៧-យោធិនពិការកំរិតថ្នាក់ ១ បានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួនមួយនាក់ ហើយអ្នកបំរើនោះត្រូវបានទទួលជាប្រចាំខែ រហូតដល់យោធិននោះស្លាប់ ស្មើនឹងបៀវត្សអប្បបរមាផ្ទាល់ខ្លួនរបស់យោធិនមានឋានន្តរសក្តិជាពលទោ ។

ខ- យោធិនពិការប្រភេទ "ខ" គ្រប់កំរិតថ្នាក់

១- យោធិនពិការប្រភេទ "ខ" ដែលក្រសួងការពារជាតិសម្រេចអោយចេញពីជួរកងយោធពល ខេមរភូមិន្ទ នឹងបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពីប្រាំបី ( ៨ ) ខែ ដោយគិតរយៈពេល បំរើកងយោធពលខេមរភូមិន្ទ ដូចក្នុងចំណុច ក៣ ខាងលើ ។

២- យោធិនពិការត្រូវបានទទួលរបបឧបត្ថម្ភតាមកំរិតថ្នាក់ពិការជាប្រចាំតាមកំរិតសមាមាត្រភាគរយនៃប្រាក់បៀវត្សផ្ទាល់ខ្លួនចុងក្រោយ របស់យោធិនពិការ :

- កំរិតថ្នាក់ ១ បានទទួលទឹកប្រាក់សរុបស្មើនឹងកៅសិប ( ៩០ ) ភាគរយនៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

- កំរិតថ្នាក់ ២ បានទទួលទឹកប្រាក់សរុបស្មើនឹងប៉ែតសិប ( ៨០ ) ភាគរយនៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

- កំរិតថ្នាក់ ៣ បានទទួលទឹកប្រាក់សរុបស្មើនឹងចិតសិប ( ៧០ ) ភាគរយនៃបៀវត្សផ្ទាល់ខ្លួនចុងក្រោយរបស់យោធិន ។

- ត្រូវបានទទួលឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬ ប្តី កូន ដូចយោធិនពិការប្រភេទ "ក" ។

គ- យោធិនពិការប្រភេទ "ក" និង "ខ" គ្រប់កំរិតថ្នាក់ ត្រូវបានទទួលរបបឧបត្ថម្ភបន្ថែម :

១-នារាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យឧបរំលឹកគុណយោធិនពលី ពិការ ( កំណត់ថ្ងៃបុណ្យភ្ជុំបិណ្ឌ ) ត្រូវបានទទួលរបបឧបត្ថម្ភស្មើនឹងទឹកប្រាក់ឧបត្ថម្ភថ្ងៃបុណ្យរបស់មន្ត្រីរាជការកំពុងធ្វើការងារ ។

២-ពេលមានជម្ងឺ របួស ឬពេលរបួសសើរី ត្រូវបានទទួលសង្គ្រោះព្យាបាលលុះជាសះស្បើយ នៅតាមមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃ ។

៣-យោធិនពិការទាំងពីរភេទ ត្រូវបានរដ្ឋជួយស្តារលទ្ធភាពពលកម្ម កាយសម្បទា និង ផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ ដោយឥតបង់ប្រាក់ ជួយបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កអោយមាន មុខរបរសមស្របតាមសមត្ថភាព និង លទ្ធភាពជាក់ស្តែង ។

៤-ចំពោះយោធិននារីពិការ ត្រូវបានទទួលឧបត្ថម្ភជាបន្ថែមនូវការធានារ៉ាប់រងសង្គម ដូច ជាស្ត្រីដែលកំពុងបំរើការងាររាជការដែរ ។

៥-ចំពោះយោធិនពិការដែលទៅបំរើការងារ នៅពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ ត្រូវ ផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីដោះស្រាយប្រាក់ឧបត្ថម្ភជំនួយ មុខរបួស និងប្រាក់សោធនិវត្តន៍វិញ ។

**មាត្រា៧ថ្មី** : រាល់ការចំណាយលើរបបឧបត្ថម្ភ ដូចជាបានចែងក្នុងមាត្រា ៤ និង ៦ ត្រូវទទួល បន្ទុកដោយថវិការដ្ឋ ។ ក្រសួងការពារជាតិ ជាអ្នកទទួលបន្ទុកដោះស្រាយដូចខាងក្រោម :

- ការចំណាយសម្រាប់បូជា ឬ បញ្ចុះសព ។
- ការចំណាយសម្រាប់ឧបត្ថម្ភជូនគ្រួសារយោធិនពលី មរណៈ បង្កស្លាប់ មួយលើកដំបូង ។
- ការចំណាយសម្រាប់ឧបត្ថម្ភបំប៉នសុខភាពយោធិនពិការ ។
- ការចំណាយសម្រាប់ឧបត្ថម្ភប្រាក់អតីតភាពការងាររបស់យោធិនពិការ មុនពេលសម្រេច អោយចេញពីជួរកងយោធពលខេមរភូមិន្ទ ។
- ការចំណាយសម្រាប់ឧបត្ថម្ភជំនួយមុខរបួស របស់យោធិនពិការទៅបន្តការងារក្នុងកង-យោធពលខេមរភូមិន្ទ ។
- ការដោះស្រាយប្រាក់បៀវត្សរបបី (៣) ខែ មុនពេលផ្ទេរយោធិនពិការទៅក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេលរង់ចាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បំពេញសំណុំលិខិតបន្តដោះស្រាយប្រាក់ឧបត្ថម្ភ ។

ក្រៅពីរបបឧបត្ថម្ភដែលក្រសួងការពារជាតិទទួលបន្ទុកដោះស្រាយ គឺក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

**មាត្រា២** : អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការកែតំរូវលើអនុក្រឹត្យលេខ៤៦អនក្រ.បក និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជា និរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ទៀ បាញ់** **ញឹក ប៊ុនឆៃ**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន
## របស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា ១.-**

តំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល ដូចមានចែងក្នុងមាត្រា ៤ វាក្យខ័ណ្ឌទី១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ត្រូវកែប្រែពីចំនួន ៣០០ រៀល ទៅចំនួន ៣៤៥ រៀល ក្នុងមួយសន្ទស្សន៍ ស្មើនឹងចំនួន ១៥ ភាគរយលើបៀវត្សមូលដ្ឋាន។

**មាត្រា ២.-**

តំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ដូចមានកំណត់ក្នុងមាត្រា ១ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ តទៅ។

មាត្រា ៣. –

អនុក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តផងដែរចំពោះនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ។

មាត្រា ៤. –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៥ . –

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

សុខ អាន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

១៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រី នៃធនាគារអភិវឌ្ឍន៍អាស៊ី និង ជំនាញការអូស្ត្រាលី ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយសម្របសម្រួល និង ជំរុញការងារស្ថាបនាផ្លូវជាតិលេខ ៥-៦ និង ៧ ប្រវែងជាង ៥០០ គីឡូម៉ែត្រ គំរោងស្តារហេដ្ឋារចនាសម្ព័ន្ធជាតិ ដែលខូចខាតដោយទឹកជំនន់ ប្រវែងជាង ៣០០ គីឡូម៉ែត្រ រួមទាំងផ្លូវដែកផង ដូចមានរាយនាមខាងក្រោម :-

| | |
|---|---|
| *១-HIS EXCELLENCY Mr. UROOJ MALIK* | *DIRECTOR OF MEKONG INFRASTRUCTURE DEPARTMENT , ADB* |
| *២-Mr. ANTHONY JUDE* | *DEPUTY COUNTRY DIRECTOR CAMBODIA RESIDENT MISSION , ADB* |
| *៣-Mr. YASUSHI TANAKA* | *TRANSPORT SPECIALIST MEKONG INFRASTRUCTURE DEPARTMENT . ADB* |

៤-*Mr.GEOFFREY W. GOWERS* *CHIEF RESIDENT ENGINEER SMEC INTERNATIONAL PTY LTD ( AUSTRALIA )*

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា . ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
B 82 -ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ..១៥...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកសាលាភូមិន្ទនគរបាល

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៣រូប ដែលបានផ្តល់ កុំព្យូទ័រ ចំនួន ៣០គ្រឿង កៅអី ៦០ និង តុកុំព្យូទ័រ ៣០ ជូនសាលាភូមិន្ទនគរបាល ព្រមទាំងជួយឧបត្ថម្ភថវិកាដល់គ្រូបង្រៀន កុំព្យូទ័រ ចំនួន ០២នាក់ សំរាប់០១ឆ្នាំ ចំណាយអស់ទឹកប្រាក់ សរុបចំនួន ២៦.៤០០ដុល្លារ ដូចមានរាយនាមខាងក្រោម :-

**ក. មេដាយមាសស្ថាបនាជាតិ :**

១-លោក **ឈី ឱដុល** អគ្គនាយកសហគ្រាស សាមចាង

២-លោក **គីម ជុំឆុក** អគ្គនាយកអង្គការក្រៅរដ្ឋាភិបាល ពន្លឺជីវិតថ្មី

**ខ. មេដាយប្រាក់ស្ថាបនាជាតិ :**

-លោកស្រី **ណូ យ៉ុងស៊ុ** ប្រធានសារមន្ទីរ សាមចាង

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង នាយកសាលាភូមិន្ទនគរបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.38

ព្រះរាជាណាចក្រកម្ពុជា

